**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Aug-2019, 15:30
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសំណើបន្ទាន់របស់ នួន ជា ទាក់ទងនឹងផលប៉ះពាល់លើ នីតិវិធីបណ្តឹងសាទុក្ខ នៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា**

---

| | |
|---|---|
| **<u>ដាក់ដោយ៖</u>** | **<u>នៅចំពោះមុខ៖</u>** |
| **<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>** | **<u>ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖</u>** |
| ពេជ អង្គ | ចៅក្រម គង់ ស្រីម ប្រធាន |
| | ចៅក្រម សោម សិរីវឌ្ឍ |
| **<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>** | ចៅក្រម Chandra Nihal JAYASINGHE |
| ជេត វណ្ណលី | ចៅក្រម Maureen HARDING CLARK |
| ហុង គឹមសួន | ចៅក្រម Florence Ndepele Mwachande MUMBA |
| គីម ម៉េងឃី | ចៅក្រម ម៉ុង មុន្នីចរិយា |

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រ៊ីនណា

Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Nushin SARKARATI
Mahesh RAI

ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Brenda J. HOLLIS (Reserve)

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

សុន អរុណ

លីវ សុវណ្ណា

Doreen Chen

គង់ សំអុន

Anta GUISSÉ

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសង្ខេបសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង០០២/០២ នៅក្នុងសវនាការសាធារណៈ[1]។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ សាលក្រមពេញលេញដោយមានសំអាងហេតុ ត្រូវបានជូនដំណឹងទៅដល់ភាគីនានា ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង[2]។ បន្ទាប់ពីមានសំណើសុំពី នួន ជា និង ខៀវ សំផន ទើបអង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ថារាល់សេចក្តីជូនដំណឹង អំពីបណ្តឹងសាទុក្ខទាំងអស់ ត្រូវដាក់ឱ្យបានមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩[3]។ ការិយាល័យសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីទាំងពីរ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[4]។

2. នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានទទួលមរណភាព។ លិខិតបញ្ជាក់មរណភាពរបស់គាត់ ត្រូវបានការិយាល័យសហព្រះរាជអាជ្ញា ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩[5]។ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់សំណើបន្ទាន់ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខ នៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ("សំណើរបស់ នួន ជា") ជាភាសាអង់គ្លេសប៉ុណ្ណោះ[6]។ នៅថ្ងៃទី១៣ ខែ

---

[1] *សូមមើល* ឯកសារ **E1/529.1** ប្រតិចារឹកសវនាការ លើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[2] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (សេចក្តីសម្រេចដោយមានសំអាងហេតុពេញលេញ ត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩)។

[3] ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹង អំពីបណ្តឹងសាទុក្ខ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១៣។

[4] ឯកសារ **E465/2/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (លើកឡើងនូវមូលដ្ឋានបណ្តឹងសាទុក្ខមួយ)។ ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ (កំណត់អំពីកំហុសឆ្គង ១៨២៤ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំនួន ៣៥៥)។ ឯកសារ **E465/3/1** សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ (លើកឡើងនូវមូលដ្ឋានបណ្តឹងសាទុក្ខ៣៥១)។

[5] ឯកសារ **F46.1** លិខិតមរណភាពរបស់ នួន ជា។

[6] ឯកសារ **F46/2** សំណើបន្ទាន់ ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខ នៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ("សំណើរបស់ នួន ជា")។

សីហា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង នួន ជា ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះនៅទទួលសំណើរបស់ នួន ជា ទាក់ទងនឹងផលប៉ះពាល់ នៃការទទួលមរណភាពរបស់ នួន ជា លើសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងការផ្តន្ទាទោសក្នុងសាលក្រមនោះ[7]។ ហេតុដូច្នេះ ទើបសហមេធាវីនាំមុខ សូមឆ្លើយតបចំពោះសំណើរបស់ នួន ជា ដោយការព្រួយបារម្ភពីការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ជាក់លាក់នានារបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីសំណើរបស់ នួន ជា ហើយនឹងគោរពទៅតាមសុភវិនិច្ឆ័យរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការសម្រេចទៅលើសំណើរបស់ នួន ជា។

## II. សិទ្ធិ

3. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១ និងសាលដីកាក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិ ក្នុងការឆ្លើយតបចំពោះសារណា ដែលបានដាក់ក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[8] ក្នុងករណីដែលសារណានោះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី[9]។

4. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា ជនរងគ្រោះមានផលប្រយោជន៍ក្នុង "សច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"។ វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថាជនរងគ្រោះទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់

[7] ឯកសារ **F46/3** សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការ នីតិវិធីលើជនជាប់ចោទ នួន ជា ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។

[8] ឯកសារ **F10/2** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៤ និង១៧ ("សេចក្តីសម្រេចអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។ សេចក្តីសម្រេចអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិភាក្សាអំពីសិទ្ធិក្នុងការឆ្លើយតប ចំពោះសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីជាពិសេស។ គោលការណ៍ដែលមាននៅក្នុងកថាខណ្ឌ ១៤ និង១៧ នៃសេចក្តីសម្រេចនោះ ត្រូវអនុវត្តចំពោះចម្លើយតបដទៃទៀត។ សូមមើល ឯកសារ **F36** សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១ ("នៅក្នុងសំណើនេះ អង្គជំនុំជម្រះយល់ស្របជាមួយ នួន ជា ត្រង់ចំណុចដែលថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំបានផ្តល់មូលដ្ឋានគាំទ្រ ថាតើសារណារបស់ខ្លួនស្របតាមគោលការណ៍ដូចបានកំណត់នៅក្នុងយុត្តិសាស្ត្រមុនៗយ៉ាងដូចម្តេចឡើយ ដូចជាថាតើសំណើរបស់ នួន ជា មានផលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួន យ៉ាងដូចម្តេចឡើយ។ ការគ្រាន់តែយោងទៅលើភាពចាំបាច់ ដើម្បីធានាបាននូវ "តុល្យភាពរបស់ភាគី" មានលក្ខណៈជាទូទៅ ពុំអាចបំពេញតាមលក្ខខណ្ឌតម្រូវ បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលបានសាលក្រមទាន់ពេលវេលាក៏ដោយ")។

[9] ឯកសារ **F10/2** សេចក្តីសម្រេចអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៧។

ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី"។ ក្នុងនាមជាជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិ ដើមបណ្ដឹងរដ្ឋប្បវេណី បើតាមច្បាប់អន្តរជាតិ មានសិទ្ធិទទួលបានការពិត និងទទួលបាននូវអង្គហេតុដែលបានកំណត់ដោយសេចក្ដីសម្រេចតាមផ្លូវតុលាការ និងសិទ្ធិទទួលបានសំណង[10]។

## III. ចម្លើយតប

5. ចម្លើយតបដែលមានការកម្រិតនេះ ត្រូវបានដាក់ជូនដើម្បីសម្ដែងនូវការព្រួយបារម្ភទាក់ទងនឹងផលប្រយោជន៍ជាក់លាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលកើតចេញពីសំណើរបស់ នួន ជា។ ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាភាគីនៃកិច្ចដំណើរការនីតិវិធីទាំងអស់នេះចាប់តាំងពីឆ្នាំ២០០៧មក ហើយដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិ ដូចជាសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ និងសិទ្ធិទទួលបានការជូនព័ត៌មាន។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង តម្រូវថា វិធានផ្ទៃក្នុងត្រូវបកស្រាយដើម្បីការពារផលប្រយោជន៍ មិនត្រឹមតែរបស់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផលប្រយោជន៍របស់ជនរងគ្រោះផងដែរ។

---

[10] គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំ ស្ដីពីសិទ្ធិទទួលបានសំណង និងការជួសជុល សម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ, មហាសន្និបាត A/RES/60/147 ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១១ (សិទ្ធិរបស់ជនរងគ្រោះ "ក្នុងការទទួលបានយុត្តិធម៌ដោយស្មើភាពនិងប្រកបដោយប្រសិទ្ធិភាព")។ កថាខណ្ឌ ១២ ("ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវទទួលបានដូចគ្នានូវ សំណងតាមផ្លូវតុលាការប្រកបដោយប្រសិទ្ធិភាព ដូចដែលមានចែងក្នុងច្បាប់អន្តរជាតិ។ សំណងដទៃទៀតដែលផ្ដល់ជូនជនរងគ្រោះ រួមមានលទ្ធភាពទាក់ទងជាមួយស្ថាប័នរដ្ឋបាល ឬស្ថាប័នដទៃទៀត ព្រមទាំងយន្តការ វិធីសាស្ត្រ និងកិច្ចដំណើរការនីតិវិធី ដែលធ្វើឡើងស្របតាមច្បាប់ជាតិ។ កាតព្វកិច្ចនានាដែលកើតឡើងតាមច្បាប់អន្តរជាតិ ដើម្បីធានានូវសិទ្ធិទទួលបានយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីយុត្តិធម៌ និងមិនលម្អៀង ត្រូវតែឆ្លុះបញ្ចាំងនៅក្នុងច្បាប់ជាតិ")។ កថាខណ្ឌ ២២(ខ)(គ) និង (ច) (សិទ្ធិទទួលបានការពេញចិត្តរួមមាន "ការអាចផ្ទៀងផ្ទាត់លើអង្គហេតុ និងការបង្ហាញការពិតទាំងស្រុង និងជាសាធារណៈ...) "ការប្រកាសជាផ្លូវការ ឬសេចក្ដីសម្រេចតាមផ្លូវតុលាការ ដែលលើកតម្កើងឡើងវិញនូវកិត្តិយស កេរ្តិ៍ឈ្មោះ និងសិទ្ធិរបស់ជនរងគ្រោះ និងមនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធិជាមួយជនរងគ្រោះ" និង "ការផ្ដន្ទាទោសតាមផ្លូវតុលាការ និងរដ្ឋបាល ចំពោះជនទាំងឡាយណាដែលទទួលខុសត្រូវ លើការរំលោភបំពាន")។ [*ឧបសម្ព័ន្ធ ១*]

6. សហមេធាវីនាំមុខសូមលើកឡើងថា ទោះបីជាកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ ហើយសាលក្រមអង្គជំនុំជម្រះសាលាដំបូង មិនមែនជាសាលក្រមស្ថាពរ សម្រាប់ នួន ជា ក្តី[11] ប៉ុន្តែសាលក្រមនៅតែមានសុពលភាព ហើយមិនមែន មោឃៈ ដូចដែលបានលើកឡើងក្នុងសំណើរបស់ នួន ជា ឡើយ[12]។ តាមពិត សាលក្រម និងកំណត់ត្រាសវនាការ នៅដដែលដោយគ្មានប្រែប្រួល និងមានសុពលភាព គ្រាន់តែមិនមានអានុភាពតាមផ្លូវច្បាប់ ចំពោះ នួន ជា[13]។ ចំណុចនេះគឺស្របគ្នាជាមួយ ទាំងសច្ចធារណ៍និរទោស[14] និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានការពិត និងសំណង រួមទាំងសិទ្ធិទទួលបានអង្គហេតុ ដែលត្រូវបានកំណត់ដោយសេចក្តីសម្រេចតាមផ្លូវតុលាការ[15]។

---

[11] ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ២៤ ("...និងការពិតដែលថា នៅក្នុងបរិបទ អ.វ.ត.ក សាលក្រមលើអង្គសេចក្តីមិនមែនជា សេចក្តីសម្រេចស្ថាពរនោះទេ រហូតទាល់តែសេចក្តីសម្រេចនេះ ឆ្លងកាត់ដំណាក់កាលនៃការប្តឹងសារទុក្ខសិន")។

[12] ឯកសារ **F46/2** សំណើបន្ទាន់ ទាក់ទងនឹងផលប៉ះពាល់លើ នីតិវិធីបណ្តឹងសាទុក្ខ នៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ២២-២៣, ៣២។

[13] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា មាត្រា ៣៩៧ ("នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ ការអនុវត្តសាលក្រមត្រូវបានផ្អាកជាបណ្តោះអាសន្ន")។ សូមមើលផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា មាត្រា៤៣៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ ("ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ")។ សហមេធាវីនាំមុខ សូមបញ្ជាក់ថា យន្តការតែមួយគត់ដែលនាំឲ្យមោឃៈសាលក្រម តាមរយៈនីតិវិធីបណ្តឹងសាទុក្ខគឺមានចែងក្នុងវិធានផ្ទៃក្នុង សូមមើលវិធាន ១០៤ (១)(ក)។

[14] ច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញ ធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៣៥ថ្មី និងមាត្រា ៣៧ថ្មី។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ សហមេធាវីនាំមុខកត់សម្គាល់ថា វិធាន ២១(១)(ឃ) បញ្ជាក់ត្រឹមថា សច្ចធារណ៍និរទោសអនុវត្ត "ដរាបណាតុលាការ មិនទាន់កាត់ទោសជាស្ថាពរ"។

[15] ដូចកំណត់សម្គាល់លេខ១០ខាងលើ។ ឯកសារ **F28** សាលដីកាសំណុំរឿង ០០១ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦៦១ ("សាលដីកាសំណុំរឿង ០០១")។ សូមមើលផងដែរ ជាឧទាហរណ៍ IACtHR, *Plan de Sánchez Massacre v. Guatemala (សំណង)*, សាលក្រមថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ៨១ [*ឧបសម្ព័ន្ធ ២*] IACtHR, រឿងក្តី *Tibi v. Ecuador (*អញ្ញត្រកម្ម អង្គសេចក្តី សំណង និង ចំណាយ) សាលក្រមថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ២៤៣ [*ឧបសម្ព័ន្ធ ៣*]។ IACtHR, រឿងក្តី *the "Juvenile Reeducation Institute" v. paraguay (*អញ្ញត្រកម្ម អង្គសេចក្តី សំណង និង ចំណាយ*)* សាលក្រមថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ២៩៩ [*ឧបសម្ព័ន្ធ៤*]។ IACtHR, រឿងក្តី *Ricardo Canese v. paraguay (*អង្គសេចក្តី សំណង និង ចំណាយ*)* សាលក្រមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ កថាខណ្ឌ ២០៥ [*ឧបសម្ព័ន្ធ ៥*]។

7. ក្នុងន័យនេះ សហមេធាវីនាំមុខ សូមរំឮកអំពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០១។ អង្គជំនុំជម្រះ បានទទួលស្គាល់នូវសារសំខាន់នៃការពេញចិត្តរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក។

> អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាសំណងផ្លូវចិត្ត និងសមូហភាពមិនអាចផ្តល់សំណងពេញលេញ ដល់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស ខាងរូបកាយឬខាងសេដ្ឋកិច្ចក្តី ក៏គោលបំណងនៃសំណងទូទៅផ្សេងទៀត ត្រូវបានបំពេញនៅចំពោះមុខ អ.វ.ត.ក ក្នុងកម្រិតដែលអាចឆ្លើយតបទៅនឹង "ការរំលោភបំពានខាងចិត្តសាស្ត្រ ផ្លូវចិត្ត និងនិមិត្តរូប"។ករណីនេះអាចសម្រេចបានតាមរយៈ "ការផ្ទៀងផ្ទាត់អង្គហេតុ និងការបង្ហាញការពិតពេញលេញជាសាធារណៈ" ដូចដែលលើកឡើងដោយសំអាងហេតុ របស់អង្គជំនុំជម្រះនានាតាមរយៈ ការចូលរួមរបស់ជនរងគ្រោះ ក្នុងកិច្ចដំណើរការនីតិវិធី និងការទទួលស្គាល់ជាបុគ្គលនៅក្នុងសាលក្រម និងការកំណត់អត្តសញ្ញាណជនរងគ្រោះដែលបង្ហាញនូវការទទួលស្គាល់ជាសាធារណៈ នូវការឈឺចាប់របស់ពួកគាត់។[16]

8. ដើម្បីឈានដល់ការសម្រេចរបស់អង្គជំនុំជម្រះលើសំណើរបស់ នួន ជា សហមេធាវីនាំមុខសូមលើកឡើងថា អង្គជំនុំជម្រះចាំបាច់ត្រូវពិចារណា ទៅលើអត្ថន័យនៃពាក្យ "អស់អានុភាពអនុវត្ត" "បញ្ចប់" និង "រំលត់" និងមិនចេញសេចក្តីសម្រេចមួយ ដែលកាត់បន្ថយនូវតម្លៃជានិមិត្តរូប នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ជាពិសេសអ្នកដែលបានមកផ្តល់សក្ខីកម្ម។ កំណត់ត្រា និងសាលក្រមដែលកើតឡើងនៅក្នុងដំណើការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ រួមជាមួយសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ នៅបន្តមានអត្ថិភាពដដែល គឺមានតែសាលក្រមអង្គជំនុំជម្រះសាលាដំបូង អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ប៉ុណ្ណោះ ដែលគ្មានអានុភាពគតិយុត្តិ។

9. សហមេធាវីនាំមុខមិនយល់ស្របជាមួយការអះអាងរបស់មេធាវីការពារក្តីឡើយដែលថា "សិទ្ធិក្នុងការទទួលបានសំណង នឹងត្រូវបានបដិសេធចោល ប្រសិនបើនីតិវិធី [ប្រឆាំង នួន ជា] ត្រូវបញ្ឈប់នៅដំណាក់កាលនេះ"[17]។ សហមេធាវីនាំមុខចាត់ទុកមតិយោបល់នេះ ថាជាការភាន់ច្រឡំ។ វិធានការសំណងដែលអង្គជំនុំជម្រះសាលាដំបូង បានអនុម័តសម្រេចក្នុងសំណុំរឿង ០០២/០២ ត្រូវបាន

---

[16] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៦៦១ (គូសបញ្ជាក់បន្ថែម)។

[17] សំណើរបស់ នួន ជា កថាខណ្ឌ ៧០។

ធ្វើឡើងតាមរយៈវិធាន២៣*ស្ទួនបួន* (៣)(ខ)។ អំណះអំណាងផ្លូវច្បាប់នេះ មិនរំពឹងទៅលើអត្ថិភាពនៃសាលក្រមស្ពាពរ ឬសាលក្រមដែលទាក់ទងនឹងជនជាប់ចោទណាមួយឡើយ។

10. អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ បានទទួលស្គាល់ថា "កាលៈទេសៈនានាដែលហួសពីការគ្រប់គ្រងរបស់អង្គជំនុំជម្រះ ដែលរួមមាន ធនធានហិរញ្ញវត្ថុមានកម្រិតដើម្បីផ្តល់សំណង អនុលោមតាមវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង និងលទ្ធភាពដែលថា ការជំនុំជម្រះនាពេលអនាគតអាចត្រូវបានរារាំងដោយសារមរណភាព ឬការពុំមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទដែលនៅមានជីវិតក្នុងសំណុំរឿង ០០២ អាចដកហូតសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដ៏គួរឲ្យសោកស្តាយ ក្នុងការទទួលសំណងចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង។ ក្នុងបរិបទនេះហើយ ទើបអង្គជំនុំជម្រះ បានព្យាយាមចាត់គ្រប់វិធានការសមហេតុផលទាំងអស់ដើម្បីកាត់បន្ថយហានិភ័យ ដែលអាចរារាំងមិនឲ្យមានការចេញសាលក្រមឲ្យទាន់ពេលវេលានៅក្នុងសំណុំរឿង ០០២/០១"[18]។ អង្គជំនុំជម្រះសាលាដំបូង បានបកស្រាយថា "សំណងថ្មីដាច់ ដោយឡែក ដែលត្រូវបានបង្កើតឡើងដោយវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុងដែលអនុលោមតាមវិធាននេះ គំនិតផ្តួចផ្តើមដែលត្រូវបានស្នើសុំជាវិធានការដែលអាចមាន ពុំនាំឲ្យមានសំណងដែលអាចអនុវត្តប្រឆាំងនឹងជនជាប់ចោទឡើយ ហើយអាចត្រូវបានបង្កើតដំណាលគ្នាជាមួយការជំនុំជម្រះបាន[19]" និងបន្តបកស្រាយថា "ទាក់ទងនឹងសំណើសុំទាមទារសំណងដែលជាបន្ទុករបស់ជន ដែលត្រូវបានផ្តន្ទាទោសដោយអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (១)(ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាពពុំអាចមានពីធម្មជាតិនៅក្នុងបរិបទកម្ពុជា នូវសំណងប្រឆាំងនឹងជនដែលត្រូវបានផ្តន្ទាទោសនៅ អ.វ.ត.ក ដែលនាំឲ្យមានលទ្ធផលប្រកបដោយអត្ថន័យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី (ដូចមានបទពិសោធន៍ក្នុងសំណុំរឿង ០០១) គឺជាផ្នែកសំខាន់នៃហេតុផលសម្រាប់ការអនុវត្តគម្រោងសំណង ដែលជាជម្រើសមួយទៀតនៅក្នុងវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង"[20]។

---

[18] ឯកសារ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ១៦១។

[19] ឯកសារ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ១៥៨។

[20] ឯកសារ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ១៥៨ កំណត់សម្គាល់

11. គោលបំណងក្នុងការបង្កើត វិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង បង្ហាញថាវិធាននេះត្រូវបានរៀបចំឡើងដើម្បីជៀសផុតមិនឱ្យមានចំណងជាប់ពាក់ព័ន្ធជាមួយជនជាប់ចោទ។ វិធាននេះមិនអនុញ្ញាតឱ្យមានការផ្តល់មូលនិធិខាងក្រៅលើសំណង ដែលផ្តោតចំពោះជនជាប់ចោទទេ។ សំណើខាងក្រៅក្នុងការធ្វើវិសោធនកម្មលើវិធាននេះ ដើម្បីឱ្យមានចំណងពាក់ព័ន្ធជាមួយជនជាប់ចោទ[21] មិនបានទទួលយកទេ ហើយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ថា សំណងដែល

---

លេខ ២៦៤ (យោងតាម សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ http://www.eccc.gov.kh/en/articles/eight-eccc-plenary-session-concludes: "កិច្ចប្រជុំពេញនាខែ កុម្ភៈ ឆ្នាំ ២០១០ បានផ្តល់សិទ្ធិអំណាចដល់អនុគណៈកម្មាធិការមួយដើម្បីស្វែងរកលទ្ធភាពដើម្បីពង្រីកវិសាលភាពនៃផែនការសំណងនាពេលបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក។ វិធានផ្ទៃក្នុងមុនៗបានបញ្ជាក់ថាសំណងក្រោមប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានផ្តល់ដោយផ្ទាល់មុខប្រឆាំងនឹងជនដែលត្រូវបានផ្តន្ទាទោស។ បទពិសោធន៍ក៏បានបង្ហាញថានៅពេលដែលជនដែលត្រូវបានផ្តន្ទាទោសគឺជាជនក្រីក្រ សំណងក្រោមគម្រោងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទំនងជាពុំទទួលលទ្ធផលជាក់ស្តែងជាដុំកំភួនសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅ ត្រូវតែបំពេញភាពអាចឱ្យទទួលយកបានយ៉ាងល្អិតល្អន់ និងលក្ខខណ្ឌតម្រូវនៃការទាមទារ។ នៅក្នុងបរិបទកម្ពុជាដ៏ជាក់លាក់នេះ លក្ខខណ្ឌទាំងនេះរមែងមានភាពលំបាកចំពោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបំពេញ។ ជាងនេះទៅទៀត ក្នុងករណីដែលជនដែលត្រូវបានផ្តន្ទាទោសពុំអនុវត្តដោយស្ម័គ្រចិត្តនូវសំណងប្រឆាំងនឹងខ្លួន ត្រូវតែមានការស្នើសុំឱ្យមានការអនុវត្តនៅចំពោះមុខតុលាការជាតិនៅកម្ពុជា។ គណៈកម្មាធិការវិធាន និងនីតិវិធីបានព្យាយាមដោះស្រាយអំពីការកំហិតទាំងនេះតាមរយៈការស្នើឡើងនូវមធ្យោបាយសំណង បន្ថែមដែលអាចប្រើប្រាស់ធនធានខាងក្រៅ ឬថវិការបស់តតិយភាគីជំនួសវិញ ដើម្បីគាំទ្រសំណង ឬផ្តល់ទម្រង់នៃសំណងដែលកាន់តែមានប្រសិទ្ធភាព")។

[21] មជ្ឈមណ្ឌលសម្រាប់យុត្តិធម៌ និងគណនេយ្យភាព សិទ្ធិក្នុងការទទួលសំណងរបស់ជនរងគ្រោះ https://cja.org/what-we-do/litigation/khmer-rouge-trials/related-resources/victims-right-to-remedy/ ("ក្នុងសំណុំរឿង ០០២ វិធានរបស់តុលាការត្រូវបានធ្វើវិសោធនកម្មដើម្បីអនុញ្ញាតឱ្យតតិយភាគីមានសិទ្ធិរ៉ាប់រងនូវចំណាយនៃសំណង។ ប្រព័ន្ធបច្ចុប្បន្នអនុញ្ញាតឱ្យចំណាយនៃសំណង ត្រូវបានរ៉ាប់រងដោយជនដែលត្រូវបានផ្តន្ទាទោស ឬដោយធនធានខាងក្រៅដែលទទួលបានដើម្បីអនុវត្តគម្រោងដែលរៀបចំឡើងដោយ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ។ ដើម្បីធានាបាននូវការចេញនៃសេចក្តីបង្គាប់ពាក់ព័ន្ធនឹងសំណងជាដំបូងចំពោះជនដែលត្រូវបានផ្តន្ទាទោស មជ្ឈមណ្ឌលសម្រាប់យុត្តិធម៌ និងគណនេយ្យភាព បានដាក់ជូននូវសំណើវិសោធនកម្មទៅលើវិធានផ្ទៃក្នុង នៅអង្គប្រជុំមួយនៅចំពោះមុខ អ.វ.ត.ក") (បានពិនិត្យមើលនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩) [*ឧបសម្ព័ន្ធ ៦*]; មជ្ឈមណ្ឌលសម្រាប់យុត្តិធម៌ និងគណនេយ្យភាព សំណើធ្វើវិសោធនកម្មនៃវិធាន២៣ *ស្ទួនបួន* (៣) នៃវិធានផ្ទៃក្នុង http://cja.org/downloads/Plenary%20Paper%20Rule%2023.pdf (បានពិនិត្យមើលនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩) [*ឧបសម្ព័ន្ធ ៧*]។

បានទាមទារតាមរយៈវិធាន ២៣ *ស្ទួនបួន* (៣)(ខ) មិនអាចត្រូវបានធ្វើឡើងចំពោះជនជាប់ចោទឡើយ[22]។

12. សំណងដែលទាមទារនៅក្រោម វិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង មិនត្រឹមតែមិនមានចំណងពាក់ព័ន្ធចំពោះជនជាប់ចោទណាមួយជាក់លាក់នោះទេ ប៉ុន្តែសំណងទាំងនោះក៏មិនមានការរំពឹងទៅលើសាលក្រមផងដែរ។ នេះសបញ្ជាក់យ៉ាងច្បាស់ថា កម្មវិធីសំណងនៅក្នុងសំណុំរឿងបច្ចុប្បន្ន ត្រូវបានបង្កើតឡើង និងអនុវត្តដំណាលគ្នាជាមួយការជំនុំជម្រះក្តីនេះ[23]។ នៅក្នុងហេតុផលនៃការអនុញ្ញាតឱ្យមានសំណងបែបនេះ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ការធ្វើបែបនេះគឺស្របទៅនឹងគោលបំណងនៃវិធាន ដែលត្រូវបានអនុម័តដើម្បី "ជម្រុញដល់ការអនុវត្តសំណងប្រកបដោយអត្ថន័យក្នុងពេលវេលាដ៏សមស្របដោយមានជំនួយពីមូលនិធិម្ចាស់ជំនួយ និងកិច្ចសហការពីខាងក្រៅ"[24]។

13. ក្របខណ្ឌនៃសំណងចំពោះមុខ អ.វ.ត.ក គឺមានលក្ខណៈពិសេស (*sui generis*)។ សំណងផ្តល់ជូន មានលក្ខណៈសមូហភាព និងផ្លូវចិត្ត ដែល "ផ្តល់ប្រយោជន៍រួមដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ" ហើយសំណងនេះ ត្រូវបានទទួលស្គាល់ ឬយល់ព្រមដោយអង្គជំនុំជម្រះ ជាជាងការរំពឹងទៅលើសាលក្រម ឬការចេញសេចក្តីបង្គាប់ចំពោះជនជាប់ចោទនោះ

---

[22] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១១២៣-១១២៤; ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៤៤១៦ កំណត់សម្គាល់លេខ ១៤២២៤។

[23] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១១២០; ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៤៤១៨ ("...អង្គជំនុំជម្រះបានដឹងថាគម្រោងទាំងនេះភាគច្រើនត្រូវបានអនុវត្តមួយផ្នែកឬទាំងស្រុងរួចហើយ។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះសូមរំលឹកឡើងវិញអំពីកង្វល់របស់សហមេធាវីនាំមុខ ទាក់ទងនឹងការលំបាកជាក់ស្តែងក្នុងការធានានូវមូលនិធិពីខាងក្រៅដើម្បីសម្រេចគម្រោងសំណង ក្រោមទម្រង់នៃការអនុវត្តដែលបានបង្កើតឡើងនៅក្នុងវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានដោះស្រាយការព្រួយបារម្ភទាំងនេះក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ រួចហើយ ដោយអនុញ្ញាតឱ្យអនុវត្តគម្រោងទាំងនេះនៅមុនពេលចេញសាលក្រម ដើម្បីធានាដល់ការសម្រេចនូវសំណងទាំងនេះប្រកបដោយអត្ថន័យក្នុងរយៈពេលសមស្រប។ អង្គជំនុំជម្រះសូមបញ្ជាក់សាជាថ្មីថា ទោះបីជាការផ្តន្ទាទោសគឺជាបុរេលក្ខខណ្ឌសម្រាប់ការផ្តល់សំណងផ្លូវចិត្តនិងសមូហភាពដោយអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (១) ក៏ដោយ ក៏ការទទួលស្គាល់គម្រោងដែលបានចាប់ផ្តើមអនុវត្តរួចហើយឬបានបញ្ចប់រួចហើយ គឺស្របតាមគោលបំណងនៃវិធាន ២៣ *ស្ទួនបួន* (៣)(ខ)")។

[24] ឯកសារ **E218/7** អនុស្សរណៈ អង្គជំនុំជម្រះសាលាដំបូង ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន៨០ *ស្ទួន* (៤)) ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១២។

ទេ[25]។ ដូច្នេះ សហាមេធាវីនាំមុខ សូមដាក់ជូនថា មរណភាពរបស់ នួន ជា មិនប៉ះពាល់ដល់សាលក្រមនៃអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ផ្ទុយទៅវិញ ផ្នែកសំណងនៅក្នុងសាលក្រម ផ្តល់ផលទៅដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីទទួលបានសំណងដ៏មានអត្ថន័យនៅក្នុងពេលសមស្របមួយ ជាពិសេស បើពិចារណាទៅលើវ័យជរារបស់ដើមបណ្ដឹងរដ្ឋប្បវេណី វ័យជរារបស់ជនជាប់ចោទ នៅចំពោះមុខ អ.វ.ត.ក និងរយៈពេលនៃនីតិវិធី។ លើសពីនេះទៅទៀត ទោះបីជាសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង មិនមានអានុភាពគតិយុត្តិទៅលើ នួន ជា តែអង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោស នួន ជា និងយល់ព្រមតាមសំណើសុំរបស់សហាមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយទទួលស្គាល់ថាជា "សំណងផ្លូវចិត្តនិងសមូហភាព"[26]។

14. សហាមេធាវីនាំមុខទទូចទាមទារថា សេចក្តីសម្រេចលើសំណើរបស់ នួន ជា ត្រូវធ្វើឡើងឲ្យបានឆាប់រហ័ស ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណី អាចទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ និងស្ថាពរ ទាក់ទងនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធី ប្រឆាំង នួន ជា។

---

[25] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៤៤១០ ("សំណងដែលមាននៅចំពោះមុខ អ.វ.ត.ក មានលក្ខណៈខុសពីសំណងដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនិងលិខិតតុបករណ៍ជាច្រើនទៀត ឬនៅចំពោះមុខតុលាការសិទ្ធិមនុស្សក្នុងតំបន់មួយចំនួន ដែលទទួលបានសិទ្ធិអំណាចក្នុងការសម្រេចលើបញ្ហាស្ដីពីការទទួលខុសត្រូវរបស់រដ្ឋ និងមានអំណាចចេញសេចក្តីបង្គាប់ឲ្យរដ្ឋទូទាត់សំណងដល់ប្រជាពលរដ្ឋរបស់ខ្លួន ក្នុងករណីតុលាការរកឃើញថារដ្ឋនោះត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងកម្រោលទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ អង្គជំនុំជម្រះមិនមានយុត្តាធិការដើម្បីបង្គាប់ឲ្យរាជរដ្ឋាភិបាលកម្ពុជា ឬអជ្ញាធរជាតិ ឬស្ថាប័នអន្តរជាតិ អនុវត្តឬចេញប្រាក់សម្រាប់វិធានការសំណងផ្សេងៗបានទេ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះក៏មិនអាចដាក់កាតព្វកិច្ចលើបុគ្គលឬស្ថាប័នដែលមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួនបាននោះដែរ។ ទោះជាយ៉ាងនេះក្តីការអនុម័តវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង បានផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះទទួលស្គាល់ថា គម្រោងជាក់លាក់មានលក្ខណៈសមស្រប ឆ្លើយតបទៅនឹងសំណងដែលទាមទារជំនួសមុខឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលរួមជាក្រុម ដើម្បីរួមចំណែកស្តារនីតិសម្បទា ការធ្វើសមាហរណកម្មសាជាថ្មី និងការស្តារសេចក្តីថ្លៃថ្នូរឡើងវិញ ប្រសិនបើអជ្ញាធរជាតិឬអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលឬម្ចាស់ជំនួយផ្សេងទៀតផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ និងទម្រង់ជំនួយផ្សេងៗទៀតដើម្បីបង្ហាញអំពីសាមគ្គីភាពជាមួយជនរងគ្រោះនៃឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ")។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៦៤១, ៦៤៤។

[26] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៣៨៤១។

## IV. សំណើសុំ

អាស្រ័យហេតុនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំដោយគោរពចំពោះអង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

(១) **ពិចារណា** ទៅលើសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលសម្រេចលើ អង្គសេចក្ដីនៃសំណើរបស់ នួន ជា។

ដោយសេចក្ដីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ | ពេជ អង្គ សហមេធាវីនាំមុខ | ភ្នំពេញ |  |